ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការរីកចម្រើននៃប្រព័ន្ធទូទាត់ឌីជីថលនៅកម្ពុជា របស់ធនាគារអេប៊ីអេ

DEVELOPMENT OF ABA BANK'S DIGITAL PAYMENT SYSTEM IN CAMBODIA

**ជំនាញ គណនេយ្យ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការរីកចម្រើននៃប្រព័ន្ធទូទាត់ឌីជីថលនៅកម្ពុជា របស់ធនាគារអេប៊ីអេ

DEVELOPMENT OF ABA BANK’S DIGITAL PAYMENT SYSTEM IN CAMBODIA

គ្រូណែនាំ៖ ញឹម ទ្រី

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទ៖ ការរីកចម្រើននៃប្រព័ន្ធទូទាត់ឌីជីថលនៅកម្ពុជារបស់ធនាគារអេប៊ីអេ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ញ៉ឹម ទ្រី

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល៤ឆ្នាំ សិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេស ក្រុមយើងខ្ញុំបានយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តន៍ កិច្ចការគណនេយ្យដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិត កាន់តែមានគុណភាពខ្ពស់សាកលវិទ្យាល័យវ៉ាន់ដា បាន បញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ពីការអនុវត្តន៍ ការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្តន៍ ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "ការរីកចម្រើននៃប្រព័ន្ធទូទាត់ឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការធ្វើម៉ាឃីតធីង។ ក្រុមយើងខ្ញុំសង្ឃឹមថា ការរៀបចំសារណាមួយនេះ និងបានចូលរួមចំណែកមួយក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានគោលបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



**តាំ វណ្ណាដែត**
ID: VI22/011



**ប៉ុន ឆ័ន**
ID: VI22/023



**ផេង វណ្ណារី**
ID: VI22/042



**មេស ម៉េង**
ID: V22/020

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យ វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់យើងខ្ញុំគ្រប់រូប និងសូមគោរពថ្លៃងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ដាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃសាកលវិទ្យាល័យ វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លៃងអំណរគុណចំពោះគ្រូណែនាំ **ញឹម ទ្រី** ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លៃងអំណរគុណដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដា ទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អំណះអំណាង**

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទស្តីពី "ការរីកចម្រើននៃប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង" នេះគឺជាស្នាដៃរបស់ក្រុមយើងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ.ពុធ..៨កើត ខែ.កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
ថ្ងៃទី២៩ខែតុលា ឆ្នាំ២០២៥
**ហត្ថលេខាតំណាងក្រុម**



តាំ វណ្ណាដែត

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

យោងទៅតាមការសិក្សាស្រាវជ្រាវកន្លងមក ក្រុមយើងខ្ញុំបានសង្កេតឃើញថាវិស័យនៃការទូទាត់ឌីជីថលនៅកម្ពុជាមានការរីចម្រើនយ៉ាងខ្លាំង និងមានប្រសិទ្ធិភាពខ្ពស់ព្រមទាំងមានការកើនឡើងពីសំណាក់អតិថិជនយ៉ាងច្រើនសន្ធឹកសន្ធាប់ ទើបធ្វើអោយក្រុមយើងខ្ញុំបានសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី "ការរីកចម្រើននៃប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង" ហើយនៅក្នុងការសិក្សាស្រាវជ្រាវនេះផងដែរ គឺមានគោលបំណងមួយចំនួនដូចជា ការសិក្សាទៅលើលក្ខខណ្ឌប្រើប្រាស់អត្ថប្រយោជន៍ដែលទទួលបានពីការរីកចម្រើននៃប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុងដើម្បីឱ្យការសិក្សាស្រាវជ្រាវកាន់តែច្បាស់ និងមានភាពងាយស្រួលក្នុងការសន្និដ្ឋាន និងផ្តល់អនុសាសន៍។

ក្រោយពីបានសិក្សាយ៉ាងយកចិត្តទុកដាក់ទៅលើប្រធានបទមួយនេះរួចមក ក្រុមយើងខ្ញុំទទួលបាននូវការយល់ដឹងកាន់តែច្បាស់អំពីប្រវត្តិនៃការកកើតប្រព័ន្ធទូទាត់ឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង។ ដោយឡែកប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្ននេះ ក៏មិនចាញ់ប្រទេសដទៃទៀតដែរ អ្នកគ្រប់គ្រងបានធ្វើការផ្តោតសំខាន់ និងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការពង្រឹងសមត្ថភាព និងមានការពន្យល់ណែនាំអំពីការទូទាត់តាមប្រព័ន្ធ ឌីជីថលនៅកម្ពុជាឱ្យមានភាពស៊ីជម្រៅជាងមុនក្នុងការបណ្តុះបណ្តាលនិយោជិត អ្នកលក់ អ្នកទិញ ស្ថាប័ន ប្រជាជនទូទាំងប្រទេសឱ្យមានភាពរីកចម្រើនទៅមុខ និងទទួលបានភាពជោគជ័យ។

សរុបសេចក្តីមក ក្រុមយើងខ្ញុំសូមធ្វើការសន្និដ្ឋានថា ប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុងសព្វថ្ងៃនេះ បានរីកចម្រើនដល់កម្រិតខ្ពស់ដោយបច្ចេកវិទ្យាផ្លាស់ប្តូរការអភិវឌ្ឍន៍សេវាកម្មធនាគារ និងធនាគារឌីជីថលផ្តល់ភាពងាយស្រួលក្នុងការទូទាត់សងប្រាក់ហើយបង្កើនសុវត្ថិភាពដល់អ្នកប្រើប្រាស់ និងធ្វើឱ្យប្រជាជនអាចប្រើប្រាស់សេវាកម្មទូទាត់នេះបានយ៉ាងល្អប្រសើរគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។

# មាតិកា


ទំព័រ

អារម្ភកថា ............................................................ i
របនាសម្ព័ន្ធ............................................................ ii
សេចក្តីថ្លែងអំណរគុណ ............................................................ ii
អំណះអំណាង ............................................................ vi
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ............................................................ v
មាតិកា............................................................ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ............................................................១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ............................................................២
១.តើការរីកចម្រើននៃប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេមានសារៈប្រយោជន៍អ្វីខ្លះដល់អ្នកប្រើប្រាស់ និងសេដ្ឋកិច្ចជាតិ?
២.តើមានយុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីគ្រប់គ្រងហានិភ័យតាមរយៈការទូទាត់សងប្រាក់តាមឌីជីថលរបស់ធនាគារអេប៊ីអេ?
១.៣ គោលបំណងនៃការស្រាវជ្រាវ............................................................២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ............................................................២
១.៤.១ ទំហំដែនកំណត់ ............................................................២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ............................................................៣
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ............................................................៣
១.៥.១ ការប្រមូលទិន្នន័យដំបូង............................................................៣
១.៥.២ ការប្រមូលទិន្នន័យបន្ទាប់ ............................................................៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ............................................................៣
១.៧ របនាសម្ព័ន្ធនៃការស្រាវជ្រាវ............................................................៤

## ជំពូកទី២
## ការរីកចម្រើននៃប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង

២.១ លក្ខណៈទូទៅនៃការរីកចម្រើនតាមប្រព័ន្ធទូទាត់ឌីជីថលរបស់ធនាគារអេប៊ីអេ..........................៥
២.១.១ និយមន័យប្រព័ន្ធ............................................................៥
២.១.២ ទ្រឹស្តីពាក់ព័ន្ធ ............................................................៥

២.១.៣ ប្រវត្តិ ...... ៥
២.១.៤ និយមន័យទូទាត់ ...... ៥
២.១.៥ ទ្រឹស្តីពាក់ព័ន្ធ ...... ៥
២.១.៦ ប្រវត្តិ ...... ៥
២.១.៧ និយមន័យឌីជីថល ...... ៦
២.១.៨ ទ្រឹស្តីពាក់ព័ន្ធ ...... ៦
២.១.៩ ប្រវត្តិ ...... ៦
២.២ សារៈប្រយោជន៍នៃការទូទាត់តាមឌីជីថល ...... ៦
២.២.១ និយមន័យសារៈប្រយោជន៍ ...... ៦
២.២.២ ទ្រឹស្តីពាក់ព័ន្ធ ...... ៦
២.២.៣ ប្រវត្តិ ...... ៦
២.៣ យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យនៃការទូទាត់សងប្រាក់តាមរយៈប្រព័ន្ធឌីជីថល ...... ៧
២.៣.១ និយមន័យយុទ្ធសាស្ត្រ ...... ៧
២.៣.២ ទ្រឹស្តីពាក់ព័ន្ធ ...... ៧
២.៣.៣ ប្រវត្តិ ...... ៧
២.៣.៤ និយមន័យការគ្រប់គ្រង ...... ៨
២.៣.៥ ទ្រឹស្តីពាក់ព័ន្ធ ...... ៨
២.៣.៦ ប្រវត្តិ ...... ៨
២.៣.៧ និយមន័យហានិភ័យ ...... ៩
២.៣.៨ ទ្រឹស្តីពាក់ព័ន្ធ ...... ៩
២.៣.៩ ប្រវត្តិ ...... ៩

## ជំពូកទី៣
## ការរីកចម្រើននៃប្រព័ន្ធទូទាត់ឌីជីថលនៅកម្ពុជា

៣.១ ស្ថានភាពទូទៅនៃការរីកចម្រើនប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង ១១
៣.១.១ ប្រវត្តិ ...... ១១
៣.១.២ លក្ខណៈទូទាត់នៃការទូទាត់របស់ធនាគារអេប៊ីអេ ...... ១២
៣.១.៣ ទិដ្ឋភាពទូទៅ ...... ១៤
៣.២ ការរីកចម្រើននៃប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង ...... ១៦
ក. រចនាសម្ព័ន្ធគ្រប់គ្រងសេវាទូទាត់សងប្រាក់ ...... ១៨
ខ. តួនាទីគ្រប់គ្រង ...... ១៩
៣.២.១ សារៈប្រយោជន៍របស់អ្នកប្រើប្រាស់នៃការទូទាត់តាមប្រព័ន្ធឌីជីថលរបស់ធនាគារអេប៊ីអេ ១៩

៣.២.២ ការកាត់បន្ថយចំណាយ និងលើកកម្ពស់សេដ្ឋកិច្ចជាតិ.....២០
៣.៣ យុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យតាមរយៈការទូទាត់សងប្រាក់របស់ធនាគារអេប៊ីអេ .....២០
៣.៣.១ យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់ធនាគារ និងដំណើរការអនុម័ត .....២០
ក. យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់ធនាគារ .....២១
ខ. ដំណើរការអនុម័ត.....២២

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង.....២៣
៤.២ ការវិភាគលើចំណុចខ្សោយ.....២៤

## ជំពូកទី៥
## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

៥.១ សេចក្ដីសន្និដ្ឋាន .....២៤
៥.២ ការផ្ដល់អនុសាសន៍ .....២៥

**ឯកសារយោង**
**ឧបសម្ព័ន**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសដែលកំពុងមានការអភិវឌ្ឍ បន្ទាប់ពីបានឆ្លងកាត់សង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំកន្លងមក។ ដោយស្ថិតក្រោមបរិយាកាសអំណោយផលនៃស្ថិរភាពនយោបាយ សន្តិភាព និងសន្តិសុខសង្គម ទើបធ្វើឱ្យប្រទេសកម្ពុជាមានភាពរីកចម្រើនលើគ្រប់វិស័យ ជាពិសេសគឺវិស័យធនាគារដែរកំពុងរីកដុះដាល និងមានវត្តមានកាន់តែច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង និងមានហេដ្ឋារចនាសម្ព័ន្ធយ៉ាងរឹងមាំ។ ដោយផ្អែកលើភាពរីកចម្រើនទាំងអស់នេះហើយ ទើបប្រមុខរាជរដ្ឋាភិបាលបានរៀបចំផែនការយុទ្ធសាស្រ្តចតុកោណបើកស្វាគមន៍ ការវិនិយោគជាតិនិងអន្តជាតិឱ្យចូលមកធ្វើការវិនិយោគដើម្បីជំរុញនូវកំណើនសេដ្ឋកិច្ច និងពង្រីកសកម្មភាពអាជីវកម្មដើម្បីបន្តអភិវឌ្ឍន៍ឱ្យកាន់តែរីកចម្រើនលូតលាស់ជាលំដាប់ ព្រមទាំងបានជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនថែមមួយកម្រិតទៀតផងដែរ។

ទន្ទឹមនិងការវិនិយោគទាំងឡាយតែងតែជួបប្រទះនូវបញ្ហាផ្សេងៗ ដើម្បីទ្រទ្រង់នៅដំណើរការអាជីវកម្មដែលត្រូវបានប្រឈមទៅនិងការខ្ចីប្រាក់ និងការផ្ទេរប្រាក់ពីប្រទេសមួយទៅប្រទេមួយ ឬពីស្ថានប័នមួយទៅស្ថាប័នមួយទៀត។ មិនថាតែអ្នកវិនិយោគប៉ុណ្ណោះទេដែលជួបប្រទះនូវបញ្ហាទាំងនេះ ជាក់ស្តែងសូម្បីតែប្រជាពលរដ្ឋដែលប្រកបអាជីវកម្មធម្មតាក៏ដូច្នោះដែរ គឺពួកគេត្រូវធ្វើការសន្សំប្រាក់ជាច្រើនឆ្នាំដើម្បីទិញសម្ភារៈថ្លៃៗដូចជា ផ្ទះ ឡាន ម៉ូតូ ដី និងរបស់របរផ្សេងៗទៀត ទាំងនេះក៏ដោយសារតែពួកគាត់ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងទៅលើការចំណាយក្នុងខណៈដែលចំណូលពួកគាត់នៅមានកម្រិតនៅឡើយប្រសិនបើពួកគាត់សន្សំប្រាក់ទាំងនោះជាប្រាក់សុទ្ធនិងរក្សាទុកប្រាក់ជាប់ខ្លួនដែលជាកត្តាមានហានិភ័យក្នុងការបាត់បង់ប្រាក់តាមរយៈការ លួច ឆក់ ប្លន់ ហើយអ្វីដែលគួរឱ្យព្រួយបារម្ភនោះគឺអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតថែមទៀតផង។ ដោយប្រការនេះហើយដើម្បីឆ្លើយតបទៅនិងតម្រូវការរបស់អតិថិជនឱ្យសមស្របនៅក្នុងសម័យបច្ចេកវិទ្យាទំនើប ទើបវិស័យធានាគារបានវិវត្តន៍ទៅជាលក្ខណៈបែបឌីជីថលដើម្បីផ្តល់សេវាហិរញ្ញវត្ថុជូនដល់អតិថិជនប្រកបដោយប្រសិទ្ធភាពខ្ពស់តាមរយៈការផ្តល់សេវាប្រាក់កម្ចី សេវាផ្ទេរប្រាក់ ការទូទាត់ប្រាក់ដោយប្រើប័ណ្ណឥណទាន ប័ណ្ណឥណពន្ធ ម៉ាស៊ីន ATM Card ជាដើមដែលសុទ្ធតែជាប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ដែលនាំមកនូវភាពងាយស្រួលក្នុងការចាយវាយទាំងក្នុង និងក្រៅប្រទេស។ កត្តាទាំងនេះហើយទើបធ្វើឱ្យវិស័យធានាគារមានភាពរីកចម្រើន និងបោះជំហានទៅមុខយ៉ាងឆាប់រហ័សក្នុងនោះយើងឃើញថាធនាគារ ក៏ជាធនាគារមួយដែលទទួលបានការគាំទ្រ និងទទួលស្គាល់ពីសំណាក់អតិថិជន និងអ្នកប្រើប្រាស់ជាច្រើននៅក្នុងប្រទេស។

ដោយមើលឃើញពីភាពសំខាន់ និងហេតុផលទាំងអស់នេះហើយទើបក្រុមរបស់យើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី «ការរីកចម្រើននៃប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ»។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការរីកចម្រើននៃការទូទាត់ឌីជីថលនៅកម្ពុជាសព្វថ្ងៃនេះ បានអភិវឌ្ឍន៍យ៉ាងលឿនក្នុងរយៈពេលពាក់កណ្តាលទសវត្សរ៍ចុងក្រោយនេះ។ ប្រទេសកម្ពុជាទទួលបានការលូតលាស់ដ៏ល្អក្នុងការប្រើប្រាស់បច្ចេកវិទ្យាទូទាត់ឌីជីថល ដោយមានការបង្ហាញពីការចូលរួមយ៉ាងច្រើនរបស់ប្រជាជន លើវិស័យនានា។ មូលហេតុដែលធ្វើឱ្យការទូទាត់ឌីជីថលមានការរីកចម្រើននៅកម្ពុជា មកពីមានការប្រើប្រាស់អ៊ីនធឺណេតកាន់តែទូលំទូលាយ អត្រានៃការចូលប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជាបានកើនឡើងយ៉ាងខ្លាំងនាពេលបច្ចុប្បន្ននេះ ដែលមានការចូលប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចច្រើនទាំងក្នុងស្រុក និងក្រៅស្រុក។ ដើម្បីចូលរួមចំណែកក្នុងផ្សព្វផ្សាយឱ្យមានការរីកចម្រើននៃការទូទាត់តាមប្រព័ន្ធឌីជីថលនៅកម្ពុជាមានប្រសិទ្ធភាព ក្រុមយើងខ្ញុំសូមលើកយកនូវសំណួរមួយចំនួនដើម្បីទុកជាទស្សនៈវិស័យ និងជាផែនទីបង្ហាញផ្លូវក្នុងការសិក្សាស្រាវជ្រាវដូចតទៅ៖

១.តើការរីកចម្រើននៃប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេមានសារៈប្រយោជន៍អ្វីខ្លះដល់អ្នកប្រើប្រាស់ និងសេដ្ឋកិច្ចជាតិ?

២.តើមានយុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីគ្រប់គ្រងហានិភ័យតាមរយៈការទូទាត់សងប្រាក់តាមឌីជីថលរបស់ធនាគារអេប៊ីអេ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ក្នុងស្នាដៃស្រាវជ្រាវទាក់ទងនឹងប្រធានបទខាងលើនេះ គឺចង់យល់ដឹងកាន់តែច្បាស់អំពីការទូទាត់សាច់ប្រាក់តាមបែបអេឡិចត្រូនិច (QR Code) របស់ធនាគារអេប៊ីអេសាខាម៉ៅសេទុង និងជម្រុញឱ្យបច្ចេកវិទ្យាដែលធនាគារប្រើប្រាស់ដើម្បីបម្រើសេវាកម្មអំពីការទូទាត់ និងបញ្ហាដែលជួបប្រទះថ្មីៗក្នុងទីផ្សារឌីជីថល ពិសេសគឺផ្តោតសំខាន់ទៅលើប្រសិទ្ធិភាពគ្រប់គ្រងឱ្យមានសុវត្ថិភាព និងទំនុកចិត្តដល់អ្នកប្រើប្រាស់ ហើយមានការរីកចម្រើនលូតលាស់យ៉ាងឆាប់រហ័សទូទាំងសកលលោក។ ហេតុនេះហើយយើងត្រូវស្វែងយល់ពីចំណុចសំខាន់ៗដូចខាងក្រោម៖

- ស្ថានភាពទូទៅនៃការទូទាត់ឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង
- ការលើកកម្ពស់បច្ចេកវិទ្យាផ្នែកទូទាត់ឌីជីថលរបស់ធនាគារអេប៊ីអេ
- ការពង្រឹងសន្តិសុខ និងការពារ
- ការបង្កើនការជួញដូរដោយប្រើប្រាស់ឌីជីថលរបស់ធនាគារអេប៊ីអេ
- ការអភិវឌ្ឍន៍សេវាកម្មជូនអតិថិជន

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដើម្បីសិក្សាស្រាវជ្រាវអំពីប្រធានបទនេះឱ្យកាន់តែស៊ីជម្រៅ មានភាពពេញលេញ និងងាយស្រួលបន្ថែមទៀត យើងត្រូវកំណត់អំពីទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវឱ្យបានជាក់លាក់ជាមុនសិន។

### ១.៤.១ ទំហំដែនកំណត់

ដំណើរការស្រាវជ្រាវនេះ គឺធ្វើឡើងដើម្បីឆ្លុះបញ្ចាំងពីដំណើរការនៃការទូទាត់សងប្រាក់តាមឌីជីថលរបស់ធនាគារអេប៊ីអេសាខាម៉ៅសេទុង។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

សម្រាប់វិសាលភាពក្នុងការសិក្សាស្រាវជ្រាវនេះ យើងបានកំណត់យកប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុងក្នុងឆ្នាំ ២០២៣-២០២៤ សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំចងក្រងជាសៀវភៅ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវត្រូវបានប្រើតាមវិធីសាស្ត្រចម្រុះ ដោយផ្តោតចម្បងទៅលើការវិភាគទិន្នន័យ និងឯកសារផ្សេងៗដែលទាក់ទងនឹងការទូទាត់ឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុងដើម្បីយកមកវិភាគ និងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់អំពីប្រសិទ្ធភាព និងការអភិវឌ្ឍនៃប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ។

សម្រាប់សំណួរទី១ ត្រូវបានប្រមូលតាមបែបគុណវិស័យតាមរយៈទិន្នន័យ និងឯកសារដែលបានមកបណ្ណាល័យតាមរយៈសិស្សច្បងជំនាន់មុនដែលសិក្សានៅ សាកលវិទ្យាល័យវ៉ាន់ដា ។

សម្រាប់សំណួរទី២ ត្រូវបានប្រមូលតាមគុណវិស័យបានមកពី ប្រភពគេហៈទំព័រដូចជា Google ChatGPT។

### ១.៥.១ ការប្រមូលទិន្នន័យដំបូង

ការប្រមូលទិន្នន័យដំបូង គឺទទួលបានការណែនាំពីលោកគ្រូដឹកនាំ និងធ្វើការសាកសួរផ្ទាល់ ជាមួយអ្នកប្រើប្រាស់ដូចជា អ្នកលក់ អ្នកទិញ ធនាគារ ឬអង្គភាពដែលពាក់ព័ន្ធដើម្បីយល់ពីតម្រូវការ និងបញ្ហានៃការទូទាត់នាពេលបច្ចុប្បន្ន។

### ១.៥.២ ការប្រមូលទិន្នន័យបន្ទាប់

ការប្រមូលទិន្នន័យបន្ទាប់ គឺបានមកពីការស្រាវជ្រាវពីក្នុងបណ្ណាល័យនានា និងគេហទំព័រក្នុងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងក្នុងគោលបំណងផ្តោតទៅលើផលប្រយោជន៍រួមនៅក្នុងការផ្តល់ចំណេះដឹង ជាជំនួយស្មារតីក្នុងការវិភាគ ជាគន្លឹះកាន់តែល្អប្រសើរក្នុងការស្រាវជ្រាវ និងគោលបំណងផ្សេងៗទៀតដែលអាចយកទៅប្រើប្រាស់បានសម្រាប់អ្នកអាន ជាពិសេសសម្រាប់និស្សិតជំនាន់ក្រោយដែលសិក្សាស្រាវជ្រាវ និងចង់យល់ដឹងអំពីប្រធានបទ ការរីកចម្រើននៃប្រព័ន្ធទូទាត់ឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង។ ការសិក្សាស្រាវជ្រាវនេះបានផ្តល់ផលប្រយោជន៍ និងចំណេះដឹងដូចជាៈ

- សម្រាប់អ្នកស្រាវជ្រាវៈ យល់ដឹងពីវិធីសាស្ត្រក្នុងការទូទាត់តាមបច្ចេកវិទ្យាឌីជីថលរបស់ធនាគារអេប៊ីអេ និងទទួលចំណេះដឹងថ្មីៗ មើលឃើញទ្រឹស្តីនានាដែលអាចជួយដល់ការអភិវឌ្ឍន៍សេវាកម្មបច្ចេកវិទ្យា។ បន្ថែមពីនេះផងដែរក៏ជួយឱ្យអ្នកស្រាវជ្រាវមានបទពិសោធន៍ថ្មី មានគំនិតច្នៃប្រឌិតដែលសមស្របទៅនិងតម្រូវការសង្គម និងសេដ្ឋកិច្ច។
- ចំពោះស្ថាប័នៈ យល់ដឹងអំពីការរីកចម្រើននៃទីផ្សារ និងការគ្រប់គ្រងយុទ្ធសាស្ត្រឌីជីថល។ ជួយបង្កើនសមត្ថភាពប្រកួតប្រជែង និងធ្វើឱ្យសេវាកម្មមានប្រសិទ្ធភាព។ លើសពីនេះ អាចជួយស្ថាប័នក្នុងការសហការជាមួយអង្គភាពពាក់ព័ន្ធបានយ៉ាងមានប្រសិទ្ធភាព។

- ចំពោះសង្គមជាតិ៖ ជម្រុញសេដ្ឋកិច្ចឱ្យកាន់តែរីកចម្រើន ផ្តល់នូវភាពងាយស្រួលដល់ប្រជាជនក្នុងការផ្ទេរសាច់ប្រាក់ទៅវិញទៅមក ផ្តល់នូវបទពីសោធន៍ថ្មីៗសម្រាប់សិស្សានុសិស្ស ប្អូនៗជំនាន់ក្រោយក្នុងការសិក្សាស្រាវជ្រាវបន្ថែមទៅលើបច្ចេកវិទ្យាទំនើបថ្មីៗ ដើម្បីឱ្យប្រទេសជាតិកាន់តែមានការអភិវឌ្ឍន៍ ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការធ្វើរចនាសម្ព័ន្ធនៃការស្រាវជ្រាវ គឺមានគោលបំណងចង់បកស្រាយឱ្យបានកាន់តែច្បាស់ពីចំណុចនីមួយៗ។ ការស្រាវជ្រាវនេះត្រូវបានបែងចែកជាប្រាំផ្នែកដែលមានដូចជា សេចក្តីផ្តើម រំលឹកទ្រឹស្តី លទ្ធផលនៃការស្រាវជ្រាវ ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍។

**ជំពូកទី១** (សេចក្តីផ្តើម)៖ លើកឡើងពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណង ទំហំ និងដែនកំណត់ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២** (រំលឹកទ្រឹស្តី)៖ ចង្អុលបង្ហាញ និងលើកឡើងនូវនិយមន័យ ប្រវត្តិផ្សេងៗ ទ្រឹស្តីរបស់អ្នកប្រាជ្ញដែលពាក់ព័ន្ធជាមួយប្រធានបទនៃការរីកចម្រើននៃប្រព័ន្ធទូទាត់តាមឌីជីថល ។

**ជំពូកទី៣** (លទ្ធផលនៃការស្រាវជ្រាវ)៖ លទ្ធផលនៃការស្រាវជ្រាវ គឺបានផ្តល់ឱ្យដឹងពីស្ថានភាពជាក់ស្តែងនៃការទូទាត់ ដឹងពីកម្រិតនៃការរីកចម្រើនក្នុងប្រព័ន្ធទូទាត់ សារៈប្រយោជន៍នៃការទូទាត់ និងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យតាមប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង។

**ជំពូកទី៤** (ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ)៖ លើកឡើងពីចំណុចខ្លាំង និងចំណុចខ្សោយនៃការរីកចម្រើននៃប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង។

**ជំពូកទី៥** (សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍)៖ ការធ្វើសេចក្តីសន្និដ្ឋានលើគ្រប់ចំណុចទាំងចំណុចខ្លាំង និងចំណុចខ្សោយ ព្រមទាំងភាពខ្វះខាតទាំងឡាយនៃការទូទាត់តាមប្រព័ន្ធឌីជីថល ក្នុងការផ្តល់ជាមតិ និងអនុសាសន៍ដើម្បីកែលម្អឱ្យប្រសើរឡើង។

# ជំពូកទី២

# ការរីកចម្រើននៃប្រព័ន្ធទូទាត់តាមឌីជីថល

## ២.១ លក្ខណៈទូទៅនៃប្រព័ន្ធទូទាត់តាមឌីជីថល

### ២.១.១ និយមន័យប្រព័ន្ធ

**ប្រព័ន្ធ** គឺជាសំណុំអង្គធាតុ ឬធាតុជាច្រើន ដែលមានទំនាក់ទំនងគ្នា និងធ្វើការសហការគ្នាដើម្បីសម្រេចបាននូវគោលបំណង និងមុខងារមួយជាក់លាក់។

### ២.១.២ ទ្រឹស្តីពាក់ព័ន្ធ

-(General Systems Theory)៖ ពន្យល់ថា ប្រព័ន្ធគ្រប់ប្រភេទមានផ្នែកជាច្រើនអន្តរទាក់ទងគ្នា ដើម្បីបំពេញមុខងារមួយ។

-ទ្រឹស្តីស៊ីប៊ែរ (Cybernetics Theory)៖ ផ្អែកលើការត្រួតពិនិត្យ និងការឆ្លើយតប (feedback) រវាងផ្នែកនានា ក្នុងប្រព័ន្ធ។

-ការគិតជាប្រព័ន្ធ (Systems Thinking)៖ គិតដោយមើលបញ្ហា ឬស្ថានភាពជាសរុប មិនស្វែងរកដំណោះស្រាយតែផ្នែកតូចៗទេ។

-ទ្រឹស្តីសង្គម បច្ចេកវិទ្យា (Socio-technical Systems Theory)៖ អះអាងថា ប្រព័ន្ធល្អត្រូវសម្របសម្រួលរវាងបច្ចេកវិទ្យា និងមនុស្ស។

-ទ្រឹស្តីប្រព័ន្ធអេកូ (Ecological Systems Theory)៖ បញ្ជាក់ថា បុគ្គលរស់នៅក្នុងបរិស្ថានជាច្រើនដែលមានឥទ្ធិពលដល់ការអភិវឌ្ឍន៍។

### ២.១.៣ ប្រវត្តិ

ប្រព័ន្ធចាប់ផ្តើមសិក្សាលម្អិតក្នុងសតវត្សទី ២០ ដោយ Ludwig von Bertalanffy ដែលបង្កើតទស្សនវិជ្ជាប្រព័ន្ធ (Systems Theory)។ ប្រព័ន្ធកុំព្យូទ័ររីកចម្រើនយ៉ាងឆាប់រហ័សចាប់ពីម៉ាស៊ីនគណនាដំបូងៗ ទៅប្រព័ន្ធបច្ចេកវិទ្យា និងបណ្តាញសង្គមបច្ចុប្បន្ន។[1]

### ២.១.៤ និយមន័យទូទាត់

**ទូទាត់** គឺជាការបង់ប្រាក់ បំពេញបំណុលដោយផ្ទាល់ ឬប្រើវិធីផ្សេងៗ ដូចជាការបង់ជាសាច់ប្រាក់ កាតឥណពន្ធ ឬប្រព័ន្ធបង់ប្រាក់អេឡិចត្រូនិច ដើម្បីបញ្ចប់ការទូទាត់នោះ។

### ២.១.៥ ទ្រឹស្តីពាក់ព័ន្ធ

ទ្រឹស្តីនេះផ្អែកលើការយល់ដឹងពីការប្តូរប្រាក់ និងតុល្យភាពផ្នែកហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនិងការបញ្ជូនប្រាក់ពីអ្នកបង់ទៅអ្នកទទួល។ វាគ្របដណ្តប់ទាំងបច្ចេកទេសសុវត្ថិភាព ទ្រឹស្តីសារព័ត៌មាន ការបញ្ជូនសំឡេង និងការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីធានាការទូទាត់ត្រឹមត្រូវ មានប្រសិទ្ធភាព និងគ្មានកំហុស។

### ២.១.៦ ប្រវត្តិ

ប្រវត្តិនៃការទូទាត់ចាប់ផ្តើមពីការផ្ទេរសាច់ប្រាក់ និងពាណិជ្ជកម្មដ៏ចាស់ទុំ ដោយមនុស្សប្រើប្រាស់រូបិយប័ណ្ណដើម្បីជំនួសទំនិញ។ បន្ទាប់មកមានការបង្កើតកាតឥណពន្ធ និងប្រព័ន្ធធនាគារដើម្បីធ្វើការទូទាត់បានងាយស្រួល និងរហ័ស។ ជាមួយការរីកចម្រើនបច្ចេកវិទ្យា ការទូទាត់ឌីជីថលនិងបង់ប្រាក់តាមអ៊ីនធឺណិតក្លាយ

[1]KHsearch. PHYSICS. (2018, June 27). *ដូចម្តេចដែលហៅថាប្រព័ន្ធ?* Retrieved from https://www.khsearch.com/qna/4940

ជារឿងធម្មតា និងទូលំទូលាយនៅសតវត្សទី ២០ និង ២១។[2]

**២.១.៧ និយមន័យឌីជីថល**

**ឌីជីថល** គឺជាប្រព័ន្ធបច្ចេកវិទ្យាស្វ័យប្រវត្តិ ដើម្បីផ្ទុក ប្រើប្រាស់ ឬបញ្ជូនព័ត៌មាន។

**២.១.៨ ទ្រឹស្តីពាក់ព័ន្ធ**

ទ្រឹស្តីពាក់ព័ន្ធនឹងឌីជីថល គឺជាការសិក្សាគន្លងថ្មី និងមូលដ្ឋានវិជ្ជាដែលពន្យល់ពីរបៀបប្រើប្រាស់ រួមទាំងដំណើរការព័ត៌មានក្នុងទ្រង់ទ្រាយឌីជីថល ដើម្បីធានាបានភាពច្បាស់លាស់ សុវត្ថិភាព និងប្រសិទ្ធភាព។ ទ្រឹស្តីនេះរួមបញ្ចូលទ្រឹស្តីអំពីសៀគ្វីឌីជីថល ការបំលែងសញ្ញា និងការបញ្ជូនព័ត៌មានក្នុងប្រព័ន្ធឌីជីថល។

**២.១.៩ ប្រវត្តិ**

ប្រវត្តិរបស់ឌីជីថលចាប់ផ្តើមពីការបង្កើត ប្រព័ន្ធលេខ (binary system) ដែលបានពិចារណាតាំងពីសម័យបុរាណមកហើយ ដោយ Leibniz នៅសតវត្សទី 17 ជាគន្លងដ៏សំខាន់សម្រាប់បច្ចេកវិទ្យា។ នៅសតវត្សទី២០ ការរីកចម្រើននៃកុំព្យូទ័រ និងសៀគ្វីអេឡិចត្រូនិច បានធ្វើឱ្យបច្ចេកវិទ្យាឌីជីថលក្លាយជាមូលដ្ឋានសម្រាប់ទូរស័ព្ទ ការបញ្ជូនព័ត៌មាន និងសារព័ត៌មាន។ ចាប់ពីឆ្នាំ 1940 ទៀតទៅ ប្រព័ន្ធឌីជីថលបានក្លាយជាគន្លងសំខាន់សម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាទំនើបៗរួមមានអ៊ីនធឺណិត និងបណ្តាញសង្គមសម័យថ្មី។[3]

## ២.២ សារៈប្រយោជន៍នៃការទូទាត់តាមប្រព័ន្ធឌីជីថល

**២.២.១ និយមន័យសារៈប្រយោជន៍**

**-សារៈប្រយោជន៍** មានន័យថា តម្លៃ ឬអត្ថប្រយោជន៍ដែលអាចទទួលបានពីរឿងអ្វីមួយ សកម្មភាពណាមួយ ដែលជួយធ្វើឱ្យមានភាពល្អប្រសើរ បានអត្ថផលសម្រាប់មនុស្ស ឬសង្គម។[4]

**-សារៈប្រយោជន៍** គឺជាអត្ថប្រយោជន៍ ភាពមានតម្លៃដែលមនុស្ស ឬសង្គម ទទួលបានពីអ្វីមួយ ដើម្បីជួយបង្កើតអត្ថប្រយោជន៍ និងការកែលម្អជីវភាព។

**២.២.២ ទ្រឹស្តីពាក់ព័ន្ធ**

ទ្រឹស្តីពាក់ព័ន្ធនៃសារៈប្រយោជន៍ គឺជាការសិក្សាអំពីអត្ថន័យ និងតម្លៃនៃអ្វីមួយដែលមានឥទ្ធិពលលើមនុស្ស ឬសង្គម។ ទ្រឹស្តីនេះពិចារណាថា សារៈប្រយោជន៍ជាគន្លងសំខាន់ក្នុងការវាយតម្លៃរបស់អ្វី ឬសកម្មភាពណាមួយ មានផលប៉ះពាល់វិជ្ជមាន ឬអវិជ្ជមាន។ វាក៏ពាក់ព័ន្ធនឹងការវាស់វែង តម្លៃសង្គម និងចិត្តវិទ្យា ដែលជួយយល់ពីមូលហេតុ និងផលប៉ះពាល់នៃសារៈប្រយោជន៍ក្នុងជីវិតប្រចាំថ្ងៃ និងការអភិវឌ្ឍសង្គម។

**២.២.៣ ប្រវត្តិ**

ប្រវត្តិនៃសារៈប្រយោជន៍យោងទៅតាមទ្រឹស្តី និងទស្សនវិជ្ជា សារៈប្រយោជន៍មានដើមកំណើតចាប់ពីសម័យបុរាណ ដោយភាសីទស្សនកិច្ច បានពិចារណាពីអត្ថន័យតម្លៃរបស់អត្ថប្រយោជន៍លើជីវិតមនុស្ស។នៅសតវត្សទី១៨ នឹង១៩ ការអភិវឌ្ឍទ្រឹស្តីអេកូណូមិក និងទស្សនវិជ្ជាសង្គម បានលើកកម្ពស់ការយល់ដឹងអំពីសារៈប្រយោជន៍ជាមូលដ្ឋានសំខាន់ក្នុងការវាយតម្លៃសង្គម និងសេដ្ឋកិច្ច។[5]

---

[2] NAC. ORY KALIP. *និយមន័យធនាគារ* Retrieved June, 12 2025 from https://www.nbc.gov.kh/payment

[3] Facebook Page. IFA. (May, 12 2025). *ប្រវត្តិរបស់ឌីជីថល.* Retrieved from https://www.facebook.com/ifa.edu.kh/posts

[4] Videos Lorning. (2022, September 04). *តើពាក្យសារៈប្រយោជន៍មានន័យដូចម្តេច?* Retrieved from https://videoslearning.com/1-937/

[5] ThmeyThemey. PHYSICS. (2018, June 27). *ដូចម្តេចដែលហៅថាប្រព័ន្ធ ?* Retrieved from https://thmeythmey.com/detail/64754

## ២.៣ យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យនៃការទូទាត់សងប្រាក់តាមរយៈប្រព័ន្ធឌីជីថល

### ២.៣.១ និយមន័យយុទ្ធសាស្ត្រ

**-យុទ្ធសាស្ត្រ** គឺជាគំនិត ឬផែនការដែលរៀបចំច្បាស់លាស់ ដើម្បីសម្រេចបានគោលបំណង នៃអាទិភាព ណាមួយ យ៉ាងមានប្រសិទ្ធភាព និងប្រសិទ្ធភាព។[6]

**-យុទ្ធសាស្ត្រ** ជាការរៀបចំផែនការប្រកបដោយការគិតគូរយ៉ាងប្រុងប្រយ័ត្ន ដើម្បីឆ្ពោះទៅរកគោលដៅ ដើម្បីដោះស្រាយបញ្ហាមួយ ឱ្យមានប្រសិទ្ធភាពក្នុងស្ថានភាពណាមួយ ឬបរិបទជាក់លាក់។[7]

### ២.៣.២ ទ្រឹស្តីពាក់ព័ន្ធ

ទ្រឹស្តីពាក់ព័ន្ធនឹងយុទ្ធសាស្ត្រ មានមូលដ្ឋានលើគំនិតថា ដើម្បីសម្រេចបានគោលដៅ ឬអភិវឌ្ឍន៍អង្គភាព មនុស្សត្រូវមានផែនការដែលប្រកបដោយទិសដៅច្បាស់លាស់។ ទស្សនៈបុរាណដូចជា Chandler បានលើកឡើងថា រចនាសម្ព័ន្ធអង្គភាពត្រូវតែធ្វើតាមយុទ្ធសាស្ត្រ។ Michael Porter បង្ហាញថា អង្គភាពអាចប្រើយុទ្ធសាស្ត្រដើម្បីប្រកួតប្រជែងក្នុងទីផ្សារ ដោយការផ្តោតលើតម្លៃ។ ទស្សនវិជ្ជាជាច្រើនបានលើកឡើងថា យុទ្ធសាស្ត្រដែលមានប្រសិទ្ធភាព គឺត្រូវផ្អែកលើធនធានខាងក្នុង និងសមត្ថភាពពិសេសរបស់អង្គភាព។ ទ្រឹស្តីទាំងនេះបង្ហាញថា យុទ្ធសាស្ត្រមិនមែនជាការធ្វើភ្លាត់ៗទេ ប៉ុន្តែជាការគិតគូរម៉ត់ចត់ ជាពិសេសក្នុងបរិបទដែលមានការប្រកួតប្រជែងកាន់តែខ្លាំង។

### ២.៣.៣ ប្រវត្តិ

យុទ្ធសាស្ត្រមានដើមកំណើតពីវិស័យយោធានៅសម័យបុរាណ ដូចជា The Art of War របស់ Sun Tzu។ ក្រោយមក វាត្រូវបានអនុវត្តន៍ ក្នុងអាជីវកម្មនៅសតវត្សទី២០ ដោយ Chandler និង Michael Porter ដោយផ្អែកលើការរៀបចំផែនការដើម្បីឈ្នះក្នុងការប្រកួតប្រជែង។ បច្ចុប្បន្នវាត្រូវបានប្រើក្នុងវិស័យនានា ដូចជាវិស័យសេដ្ឋកិច្ច វិស័យអប់រំ និងការអភិវឌ្ឍសង្គម។[8]

### ២.៣.៤ និយមន័យការគ្រប់គ្រង

**-ការគ្រប់គ្រង** គឺជាដំណើរការរៀបចំ គ្រប់គ្រង ការត្រួតពិនិត្យ និងពង្រឹងប្រព័ន្ធទូទាត់តាមបច្ចេកវិទ្យាឌីជីថល ដើម្បីធានាបាននូវប្រសិទ្ធភាព សុវត្ថិភាព ទំនុកចិត្ត និងភាពរលូននៃប្រតិបត្តិការទូទាត់នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ។[9]

**-ការគ្រប់គ្រង** (Management) គឺជាដំណើរការនៃការប្រើប្រាស់ធនធាន ទាំងឡាយនៅក្នុងស្ថាប័នឱ្យទទួលបានជោគជ័យដល់ស្ថាប័ន ដោយមានការធ្វើផែនការ ការរៀបចំចាត់តាំង ការដឹកនាំ និងការត្រួតពិនិត្យ។ ដើម្បីធ្វើឱ្យស្ថាប័នមួយដំណើរការទៅមុខ និងរីកចម្រើនប្រកបដោយភាពរឹងមាំបាន វាតម្រូវឱ្យស្ថាប័ននោះមានការគ្រប់គ្រងដ៏ត្រឹមត្រូវ។

---

[6] Tmey Tmey. (2017, December 27). *យុទ្ធសាស្ត្រ និងវិធីសាស្ត្រមានន័យខុសគ្នាដូចម្តេច?* Retrieved June, 12 2025 from https://thmeythmey.com/detail/59938

[7] Tmey tmey. (2017, December 27). *យុទ្ធសាស្ត្រ និងវិធីសាស្ត្រមានន័យខុសគ្នាដូចម្តេច?* Retrieved June, 12 2025 from https://thmeythmey.com/detail/59938

[8] KHsearch. គ្រប់គ្រង.(2025, May 29). *អ្វីទៅជាយុទ្ធសាស្ត្រ?* Retrieved June, 12 2025 from https://www.khsearch.com/qna/31418

[9] KHsearch. គ្រប់គ្រង. (2025, May 29). *អ្វីទៅជាការគ្រប់គ្រង?* Retrieved June, 12 2025 from https://www.khsearch.com/qna/31421




**២.៣.៥ ទ្រឹស្តីពាក់ព័ន្ធ**

ទ្រឹស្តីការគ្រប់គ្រងជួយយើងឱ្យយល់ពីរបៀបដឹកនាំ និងគ្រប់គ្រងការងារឱ្យមានប្រសិទ្ធភាព ដែលមានទ្រឹស្តីសំខាន់ៗដូចជា៖

-ទ្រឹស្តីបុរាណ ដែលផ្តោតលើការរៀបចំ និងធ្វើការងារជាមុខងារ ដូចជាការធ្វើផែនការរៀបចំការដឹកនាំ និងត្រួតពិនិត្យ។

-ទ្រឹស្តីអាកប្បកិរិយា ដែលផ្តោតលើសង្គម និងមនុស្សបង្ហាញថាការយកចិត្តទុកដាក់ដល់បុគ្គលិកជួយបង្កើនផលិតភាពការងារ។

-ទ្រឹស្តីប្រព័ន្ធ ដែលឱ្យយើងឃើញអង្គភាពជាប្រព័ន្ធមួយដែលមានបំណែកផ្សេងៗធ្វើការសម្របសម្រួលគ្នា។

-ទ្រឹស្តីលទ្ធផលអាស្រ័យលើស្ថានភាព ដែលនិយាយថាវិធីគ្រប់គ្រងល្អ គឺអាស្រ័យទៅលើបរិបទ និងបញ្ហា។ ទ្រឹស្តីទាំងនេះជួយដល់ការដឹកនាំ និងធ្វើការងារឱ្យមានប្រសិទ្ធភាព និងភាពជោគជ័យ។

**២.៣.៦ ប្រវត្តិ**

ការគ្រប់គ្រងមានប្រវត្តិជាយូរណាស់មកហើយ តាំងពីពេលដែលមនុស្សចាប់ផ្តើមធ្វើការរួមគ្នា ហើយត្រូវការជំនួយក្នុងការដឹកនាំ និងរៀបចំការងារ។ ចាប់ពីអាណាចក្រចាស់ៗដូចជាអេហ្ស៊ីប ប្រទេសចិន និងបារាំង មានអ្នកដឹកនាំដែលបានប្រើប្រាស់គន្លងនានា ដើម្បីធ្វើឱ្យការងារប្រកបដោយប្រសិទ្ធភាព។ នៅសតវត្សទី ១៩ និង២០ បានបង្កើតទ្រឹស្តីគ្រប់គ្រងជាច្រើនដូចជា ទ្រឹស្តីវិទ្យាសាស្ត្រគ្រប់គ្រងរបស់ Frederick Taylor

ដែលផ្តោតលើការកែលម្អការងារ និងការផ្តល់ប្រសិទ្ធភាពខ្ពស់។ បន្ទាប់មកមានទ្រឹស្តីអាកប្បកិរិយា ដែលចង់ផ្តោតលើមនុស្ស និងទំនាក់ទំនងក្នុងការងារ។

សព្វថ្ងៃ ការគ្រប់គ្រងបានរីកចម្រើនកាន់តែទូលំទូលាយ មានទ្រឹស្តីសម័យទំនើបដូចជា ទ្រឹស្តីប្រព័ន្ធ និងទ្រឹស្តីលទ្ធផលអាស្រ័យលើបរិបទ ដែលជួយឱ្យការគ្រប់គ្រងមានភាពបត់បែន និងសម្របសម្រួលជាមួយបរិបទ និងបច្ចេកវិទ្យា។[10]

**២.៣.៧ និយមន័យហានិភ័យ**

**-ហានិភ័យ** មានន័យថា ហេតុ បញ្ហាប្រឈមផ្សេងៗដែលអាចនាំឱ្យបាត់បង់ ឬខូចខាត។[11]

**-ហានិភ័យ** គឺជាភាពមិនប្រាកដនៃការកើតមានបញ្ហា អំពើដែលអាចនាំឱ្យប៉ះពាល់ ភាពអវិជ្ជមានដល់មនុស្ស អង្គភាព ឬសកម្មភាពណាមួយ។

**-ហានិភ័យ** គឺជាបញ្ហាដែលអាចកើតឡើងក្នុងដំណើរការប្រើប្រាស់ និងប្រតិបត្តិការនៃប្រព័ន្ធទូទាត់តាមបច្ចេកវិទ្យាឌីជីថល ដែលអាចប៉ះពាល់ដល់សុវត្ថិភាព ភាពទុកចិត្ត ប្រសិទ្ធភាព និងស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុជាសរុប។

**២.៣.៨ ទ្រឹស្តីពាក់ព័ន្ធ**

ទ្រឹស្តីពាក់ព័ន្ធនឹងហានិភ័យ ត្រូវបានអភិវឌ្ឍឡើងដើម្បីជួយមនុស្សធ្វើសេចក្តីសម្រេច និងការគ្រប់គ្រងក្នុងជីវិតពេញមួយសតវត្ស។ ទ្រឹស្តីទាំងនេះជាសំនុំគំនិត និងបម្រែបម្រួលវិជ្ជាជីវៈនានា ដែលសិក្សា និងគ្រប់គ្រងហានិភ័យនៅក្នុងស្ថានការណ៍ផ្សេងៗ។[12]

**២.៣.៩ ប្រវត្តិ**

ហានិភ័យមានដើមកំណើតពីសម័យបុរាណ ដែលមនុស្សយល់ពីហានិភ័យតាមជំនឿ។ នៅសតវត្សទី ១៧ ការអភិវឌ្ឍន៍វិទ្យាសាស្ត្រហានិភ័យចាប់ផ្តើមកើតឡើង ដោយប្រើក្នុងការគណនាហានិភ័យពាក់ព័ន្ធនឹងជានារ៉ាប់រង។ សតវត្សបន្ទាប់ៗ មានការអភិវឌ្ឍទ្រឹស្តីសេដ្ឋកិច្ច សង្គម និងការគ្រប់គ្រងហានិភ័យយ៉ាងទូលំទូលាយ ដូចជា Risk Management, Risk Perception និង Resilience Theory។

[10] KHsearch. គ្រប់គ្រង. (2019, December 05). *អ្វីជាការគ្រប់គ្រង?* Retrieved from https://www.khsearch.com/qna/314110

[11] Facebook Page. 1k Share. (2020, November 11). *ពាក្យហានីភ័យ.* Retrieved from https://web.facebook.com/share/p/16c47kF1nn/

[12] Chart GPT. *ទ្រឹស្តីពាក់ព័ន្ធនឹងហានិភ័យ.* Retrieved from https://chatgpt.com/

# ជំពូកទី៣

# ការរីកចម្រើននៃប្រព័ន្ធទូទាត់ឌីជីថលនៅកម្ពុជា

## ៣.១ ស្ថានភាពទូទៅនៃការរីកចម្រើនប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ

### ៣.១.១ ប្រវត្តិ

ប្រវត្តនៃការរីកចម្រើនតាមប្រព័ន្ធទូទាត់ឌីជីថលនៅកម្ពុជាបានវិវត្តន៍ឡើងយ៉ាងខ្លាំងក្នុងពេលថ្មីៗនេះដោយមានការចូលរួមពីរាជរដ្ឋាភិបាល ស្ថាប័នហិរញ្ញវត្ថុ និងក្រុមហ៊ុនឯកជនជាច្រើន។ ខាងក្រោមនេះជាប្រវត្តិសង្ខេបនៃការរីកចម្រើនប្រព័ន្ធទូទាត់ឌីជីថលរបស់ធនាគារអេប៊ីអេ៖ **សាខា ម៉ៅសេទុង** ត្រូវបានបើកដំណើរការជាផ្លូវការដោយ ABA Bank ចាប់តាំងពី មុនឆ្នាំ 2018 ក្នុងទីតាំងដើមនៅលើផ្លូវម៉ៅសេទុង។ វាជាសាខាមួយក្នុងចំណោមសាខាជាប់នឹងតំបន់ពាណិជ្ជកម្មសំខាន់ៗនៅភ្នំពេញដូចជា ផ្សារទួលទំពូង និងបឹងកេងកង។

**១. កំណើត និងការបង្កើតដំបូង (1996 – 2009)** ABA ត្រូវបានបង្កើតឡើងនៅ ឆ្នាំ 1996 ដោយមានឈ្មោះពេញថា Advanced Bank of Asia Limited។ ដំបូងធនាគារនេះផ្តោតលើ អតិថិជនសហគ្រាស និងអាជីវកម្មតូចៗ នៅក្នុងទីក្រុងភ្នំពេញ។ ក្នុងរយៈពេលដំបូងនេះ ABA ធ្វើការជាក្រុមហ៊ុនឯកជនតូចមួយប៉ុណ្ណោះ។

**២. ការវិវត្តន៍រហ័ស និងពង្រីកសាខា (2010–2014)** ចាប់ពីឆ្នាំ 2010 ABA ចាប់ផ្តើមការរីកចម្រើនយ៉ាងឆាប់រហ័ស ដោយបើកសាខាថ្មីជាច្រើននៅរាជធានីនិងខេត្ត។ ជាពិសេស ABA ចាប់ផ្តើមផ្តោតលើ សេវាធនាគារដល់ប្រជាពលរដ្ឋ (retail banking) ជាមួយនឹងបច្ចេកវិទ្យាឌីជីថលនានា។

**៣. ការវិនិយោគពី National Bank of Canada ( 2014–2019 )** ក្នុងឆ្នាំ 2014, National Bank of Canada (NBC) បានចូលវិនិយោគជាដំបូងក្នុង ABA ដោយកាន់ភាគហ៊ុន 10%។ NBC បន្តបន្ថែមភាគហ៊ុនរហូតដល់ 100% នៅ ខែតុលា 2019។ ទន្ទឹមនឹងនោះ ABA ទទួលបានការគាំទ្ររយៈពេលវែងពីធនាគារអន្តរជាតិ និងបន្តបង្កើនសុវត្ថិភាព និងប្រព័ន្ធគ្រប់គ្រងស្តង់ដារ។

**៤. ការបង្ហាញខ្លួនជាអ្នកដឹកនាំធនាគារឌីជីថល (2020–បច្ចុប្បន្ន)** ABA បានក្លាយជាធនាគារដែលបំពាក់នូវបច្ចេកវិទ្យាជាងគេនៅកម្ពុជា ដូចជា៖ ABA Mobile App: កម្មវិធី ABA Mobile បានក្លាយជាស៊ីស្ទែម "financial super app" ជាលើកដំបូងនៅកម្ពុជា។ Face Pass Secure និង In-App Chat: ធ្វើឱ្យអតិថិជនអាចចូលប្រើសេវាបានយ៉ាងមានសុវត្ថិភាព។ PayWay Gateway: ប្រព័ន្ធទូទាត់តាមអ៊ិនធឺណេតប្រើប្រាស់ពេញនិយមសម្រាប់អាជីវកម្ម។

**៥. ការទទួលស្គាល់អន្តរជាតិ និងពានរង្វាន់** ABA ត្រូវបានក្រុមការងារអន្តរជាតិដូចជា Euromoney, The Banker, Asiamoney, និង Global Finance Magazine ផ្តល់ជាពាន "Best Bank in Cambodia" សម្រាប់ច្រើនឆ្នាំជាប់ៗគ្នា។ ឧទាហរណ៍៖ នៅឆ្នាំ 2024, ABA ត្រូវបានប្រកាសជាធនាគារល្អបំផុតប្រចាំកម្ពុជា។

**៦. បច្ចុប្បន្នភាព និងស្ថានភាពហិរញ្ញវត្ថុ** ABA មាន បណ្តាញសាខាច្រើនជាង 90 និងម៉ាស៊ីន ATM ABA 24/7 ជាច្រើនស្ថិតនៅទូទាំងប្រទេស។ នៅ ឆ្នាំ 2024, ABA ទទួលបាន វិនិយោគបន្ថែម USD 220 million ដើម្បីពង្រឹងស្ថិរភាពហិរញ្ញវត្ថុ និងទំនួលខុសត្រូវសង្គម។

**៧. វិស័យសង្គម និងសេដ្ឋកិច្ច** ABA មានវិស័យច្បាស់លាស់ក្នុងការគាំទ្រសហគមន៍ ដោយផ្តល់ជំនួយក្នុងការអប់រំ សុខាភិបាល និងវិស័យបច្ចេកវិទ្យា។ ក៏ប៉ុន្តែ ABA ក៏មានរង្វាន់ "Gold Certificate" ពីអគ្គនាយកដ្ឋានពន្ធដារផងដែរសម្រាប់ការបង់ពន្ធយ៉ាងស្មោះត្រង់ និងទៀងទាត់។




**៣.១.២ លក្ខណៈទូទាត់នៃការទូទាត់របស់ធនាគារអេប៊ីអេ**

លក្ខខណ្ឌនៃដំណើរការទូទាត់របស់ធនាគារ ABA អាចបែងចែកបានជា ៣ ប្រភេទចម្បង៖ ទូទាត់ក្នុងស្រុក (តាម ABA Mobile និងប្រព័ន្ធ Bakong), ទូទាត់អន្តរជាតិ (តាម SWIFT), និងវិធីទូទាត់សម្រាប់ពាណិជ្ជកម្ម (Trade Finance)។

- សម្រាប់ការទូទាត់ក្នុងស្រុក ធនាគារផ្តល់សេវាតាមកម្មវិធី ABA Mobile ដែលងាយស្រួលក្នុងការទូទាត់វិក្កយបត្រ និងផ្ទេរប្រាក់។ ការផ្ទេរប្រាក់ទៅគណនីផ្សេងៗក្នុងស្រុកអាចមានកម្រៃតិចតួច និងធានាសុវត្ថិភាពខ្ពស់។
- ក្នុងករណីទូទាត់ប្រាក់អន្តរជាតិ តម្រូវឱ្យមានព័ត៌មានពេញលេញអំពីអ្នកទទួលប្រាក់ និងធនាគារABA រួមទាំងកូដ SWIFT។ កម្រៃសេវាការផ្ទេរអន្តរជាតិអាស្រ័យលើចំនួនប្រាក់ និងរូបិយប័ណ្ណ។ ចំពោះការទូទាត់សម្រាប់ការជួញដូរ ធនាគារផ្តល់ជម្រើសដូចជា ការទូទាត់ជាមុន ការបើកគណនីចំហ ការប្រមូលឯកសារលិខិតឥណទាន និងប័ណ្ណធានា ដែលអាចជ្រើសរើសប្រើអាស្រ័យលើស្ថានភាពអាជីវកម្មនីមួយៗ។ សរុបគឺ ABA ផ្តល់លក្ខខណ្ឌទូទាត់ដែលបត់បែន តាមបំណងប្រើប្រាស់ និងមានសុវត្ថិភាព។


ស្កេន QR រួចផ្ទៀងផ្ទាត់ ឈ្មោះអ្នកទទួល
ឲ្យច្បាស់មុនផ្ទេរប្រាក់
កុំឲ្យផ្ទេរខុស
KHQR
UN SOVANNRA
3:10
ABA ស្កេន
US
UN SOVANNRA
100,000
Thanks
Lunch
Coffee
ABA
NATIONAL BANK OF CANADA GROUP


ផ្ទៀងផ្ទាត់ ព័ត៌មានអ្នកទទួលឲ្យច្បាស់
មុនចុចបង់
Neary Coffee
18,000
ABA PAY
Scan. Pay. Done.
NEARY COFFEE
រូបិយប័ណ្ណ
ឈ្មោះអ្នកទទួល
KHQR
ABA
NATIONAL BANK OF CANADA GROUP


កាតប្លាស្ទិក ABA
ទូទាត់ភ្លាម ទទួលសារដំណឹងភ្លាមៗ ក្នុង ABA Mobile
VISA
UnionPay
ABA BANK
PLATINUM
7:28
ABA MOBILE
now
UNIQLO STORE
Mon 30 15°
7:28
ធ្វើដំណើរកាន់តែសុវត្ថិភាព
មិនបាច់ដាក់សាច់ប្រាក់តាមខ្លួនច្រើន
ចាយរូបិយប័ណ្ណណាក៏បាន
ពេញដោយទំនុកចិត្ត
ABA
NATIONAL BANK OF CANADA GROUP

**៣.១.៣ ទិដ្ឋភាពទូទៅ**

ធនាគារ ABA សាខាម៉ៅសេទុង មានរចនាបថទាន់សម័យ ស្អាត និងបរិយាកាសសមរម្យសម្រាប់អតិថិជន។ ផ្ទៃខាងក្នុងត្រូវបានរៀបចំយ៉ាងស្អាត មានកៅអីសម្រាប់អង្គុយរង់ចាំ និងតំបន់ផ្តល់សេវាដែលអាចប្រើប្រាស់បានយ៉ាងមានប្រសិទ្ធភាព។ សាខានេះដូចជាសាខាផ្សេងៗរបស់ ABA គឺមានផ្តល់សេវាកម្មទូទៅដូចជា៖ បញ្ចូលប្រាក់ ដកប្រាក់ ផ្ញើប្រាក់ ទទួលប្រាក់ និងសេវាដទៃទៀតតាមរយៈការទំនាក់ទំនងផ្ទាល់ជាមួយបុគ្គលិក។ ក្រៅពីនេះ ក៏មានម៉ាស៊ីនស្វ័យប្រវត្តិ និង self-banking ដែលអាចប្រើប្រាស់បានគ្រប់ពេលវេលា។ ABA គឺជាធនាគារឯកជនធំជាងគេមួយនៅកម្ពុជា មានបណ្តាញសាខា និងម៉ាស៊ីនស្វ័យប្រវត្តិជាច្រើនទូទាំងប្រទេស។ វាតែងតែទទួលបានការទទួលស្គាល់ និងរង្វាន់ជាតិ និងអន្តរជាតិជាបន្តបន្ទាប់ក្នុងនាម Best Bank in Cambodia។ បន្ថែមពីនេះ ABA មានសេវាឌីជីថលកំពូលដូចជា ABA Mobile និង ABA Business ដែលងាយស្រួលប្រើ សុវត្ថិភាព និងឆ្លើយតបទាន់ពេលវេលាចំពោះតម្រូវការរបស់អតិថិជនផ្ទាល់ខ្លួន និងអាជីវកម្ម។




ABA
BANK
10
9
8
7




## ៣.២ ការរីកចម្រើននៃប្រព័ន្ធទូទាត់ឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង

ប្រព័ន្ធទូទាត់ឌីជីថលរបស់ ABA សាខាម៉ៅសេទុង ត្រូវបានអភិវឌ្ឍតាមគោលនយោបាយសកលរបស់ ABA Bank ដែលផ្តោតលើការបង្កើតសេវាដែលងាយស្រួល ប្រើបានគ្រប់ពេល និងមានសុវត្ថិភាព។ ការរីកចម្រើននេះអាចពិពណ៌នាបានតាមជំហាន និងលក្ខណៈសំខាន់ៗដូចខាងក្រោម៖

- ABA Mobile បានក្លាយជាមជ្ឈមណ្ឌលសំខាន់សម្រាប់អតិថិជនប្រើប្រាស់ ដោយអាចធ្វើប្រតិបត្តិការបង់ប្រាក់ ផ្ទេរប្រាក់ ទទួលប្រាក់ និងគ្រប់គ្រងគណនីដោយមិនចាំបាច់ទៅកាន់សាខា។
- ABA PayWay និង ABA KHQR គឺជាប្រព័ន្ធទូទាត់ឌីជីថលសំខាន់ ដែលអាជីវកម្ម និងហាងទំនិញអាចទទួលប្រាក់ពីអតិថិជនតាមរយៈ QR code ឬបង់តាមអនឡាញបានយ៉ាងងាយស្រួល។
- សេវា Self-banking និង ATM ត្រូវបានភ្ជាប់ជាមួយប្រព័ន្ធឌីជីថល ABA ដើម្បីអោយអតិថិជនធ្វើប្រតិបត្តិការដោយខ្លួនឯង 24 ម៉ោង ដូចជាការដកប្រាក់ ដាក់ប្រាក់ ឬបង់ថ្លៃសេវា។

- ការគាំទ្រអាជីវកម្មតូច និងមធ្យម តាមរយៈ ABA Business ដែលអនុញ្ញាតឱ្យមានការទូទាត់ប្រាក់ខែ (Payroll), បង់ថ្លៃទំនិញ និងគ្រប់គ្រងហិរញ្ញវត្ថុដោយប្រើប្រព័ន្ធឌីជីថល។ សុវត្ថិភាពឌីជីថល ត្រូវបានបង្កើនជាបន្តបន្ទាប់ ដោយប្រើការផ្ទៀងផ្ទាត់ពីរជាន់ (Two-Factor Authentication) និងបច្ចេកវិទ្យាការពារ Transaction Monitoring ដើម្បីធានាថាប្រតិបត្តិការមានសុវត្ថិភាព។ សាខាម៉ៅសេទុងទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធទាំងនេះដូចគ្នា ដោយអតិថិជនក្នុងតំបន់អាចប្រើប្រាស់សេវាឌីជីថលបានដូចជាសាខាផ្សេងៗទៀត ហើយអាចធ្វើប្រតិបត្តិការជាមួយ ABA ដោយងាយស្រួលទោះបីនៅតែឆ្ងាយពីទីសាខាក៏ដោយ។






### ក រចនាសម្ព័ន្ធគ្រប់គ្រងសេវាទូទាត់សងប្រាក់

រចនាសម្ព័ន្ធគ្រប់គ្រងសេវាទូទាត់សងប្រាក់របស់ ABA ត្រូវបានរៀបចំឱ្យមានប្រសិទ្ធភាព និងសុវត្ថិភាព ដោយមានកម្រិតគ្រប់គ្រងច្បាស់លាស់។ នៅកម្រិតខ្ពស់ គឺក្រុមប្រឹក្សាភិបាល និងក្រុមគ្រប់គ្រងកំពូល ដែលមានតួនាទីកំណត់យុទ្ធសាស្ត្រ និងគោលនយោបាយទូទៅសម្រាប់ប្រព័ន្ធទូទាត់ ដើម្បីអោយស្របតាមច្បាប់ និងស្តង់ដារអន្តរជាតិ។ នៅកម្រិតប្រតិបត្តិការត្រូវបានគ្រប់គ្រងដោយផ្នែកប្រតិបត្តិការបង់ប្រាក់ ដែលមានភារកិច្ចអនុវត្តប្រតិបត្តិការទូទាត់ទាំងក្នុងប្រទេស និងអន្តរជាតិ រួមទាំងការបង់ប្រាក់តាមប្រព័ន្ធឌីជីថល។ ផ្នែកបច្ចេកវិទ្យា និងឌីជីថលគឺជាចំណុចស្នូល ដែលគ្រប់គ្រងប្រព័ន្ធ ABA Mobile, ABA PayWay, ABA KHQR និងម៉ាស៊ីនស្វ័យប្រវត្តិ ដើម្បីធានាថាការទូទាត់មានភាពរលូន និងទាន់សម័យ។ ក្រៅពីនេះ មានផ្នែកគ្រប់គ្រងហានិភ័យ និងអនុលោម ដែលត្រួតពិនិត្យប្រតិបត្តិការទូទាត់ទាំងអស់ ដើម្បីការពារពីហានិភ័យ

ប្រព័ន្ធ និងធានាថាមានការអនុលោមច្បាប់ប្រកបដោយតម្លាភាព។ ផ្នែកសេវាអតិថិជនក៏មានតួនាទីសំខាន់ក្នុងការជួយដោះស្រាយបញ្ហាប្រតិបត្តិការទូទាត់ និងផ្តល់ការគាំទ្រយ៉ាងឆាប់រហ័ស។ បន្ថែមពីនេះ ABA ក៏មានផ្នែកទំនាក់ទំនងអន្តរជាតិ និងដៃគូ ដែលធ្វើការភ្ជាប់ប្រព័ន្ធទូទាត់ជាមួយ SWIFT, Visa, MasterCard, UnionPay និងប្រព័ន្ធ Bakong របស់ធនាគារជាតិនៃកម្ពុជា។ រចនាសម្ព័ន្ធទាំងមូលនេះធ្វើឱ្យ ABA អាចផ្តល់សេវាទូទាត់បានទូលំទូលាយ គ្របដណ្តប់ទាំងអតិថិជនបុគ្គល អាជីវកម្មតូច និងក្រុមហ៊ុនធំៗ ដោយមានប្រសិទ្ធភាព និងសុវត្ថិភាពខ្ពស់។

**ខ តួនាទីគ្រប់គ្រង**

តួនាទីគ្រប់គ្រងសេវាទូទាត់សងប្រាក់របស់ ABA គឺមានភារកិច្ចកំណត់យុទ្ធសាស្ត្រ និងគោលនយោបាយស្របតាមច្បាប់ និងស្តង់ដារអន្តរជាតិ គ្រប់គ្រងប្រតិបត្តិការបង់ប្រាក់ប្រចាំថ្ងៃឱ្យមានភាពរលូន និងមានប្រសិទ្ធភាព បង្កើត និងថែទាំប្រព័ន្ធឌីជីថលឱ្យអតិថិជនប្រើបានងាយស្រួល និងមានសុវត្ថិភាព ត្រួតពិនិត្យហានិភ័យដើម្បីទប់ស្កាត់ការលួចបន្លំ និងធានាអនុលោមច្បាប់ ផ្តល់សេវាគាំទ្រដល់អតិថិជន និងដោះស្រាយបញ្ហាប្រតិបត្តិការបង់ប្រាក់ ហើយភ្ជាប់ទំនាក់ទំនងជាមួយធនាគារ និងបណ្តាញអន្តរជាតិដើម្បីពង្រីកសេវាកម្ម។

**៣.២.១ សារៈប្រយោជន៍របស់អ្នកប្រើប្រាស់នៃការទូទាត់តាមប្រព័ន្ធឌីជីថលរបស់ធនាគារអេប៊ីអេ**

សារៈប្រយោជន៍សំខាន់ៗដែលអ្នកប្រើប្រាស់ទទួលបានពីការទូទាត់តាមប្រព័ន្ធឌីជីថលរបស់ធនាគារ ABA មានច្រើនមុខ ដែលជួយឱ្យប្រតិបត្តិការហិរញ្ញវត្ថុមានភាពងាយស្រួល និងទាន់សម័យ។ ការទូទាត់តាមប្រព័ន្ធឌីជីថលអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការបានគ្រប់ពេលវេលា គ្រប់ទីកន្លែង ដោយមិនចាំបាច់ទៅកាន់សាខា។ អ្នកប្រើប្រាស់អាចផ្ទេរប្រាក់ ទទួលប្រាក់ បង់ថ្លៃទំនិញ ឬសេវាកម្ម និងគ្រប់គ្រងគណនីតាមទូរស័ព្ទដៃបានភ្លាមៗ។ ការប្រើប្រាស់ ABA Mobile និង ABA PayWay ក៏ផ្តល់ភាពងាយស្រួលក្នុងការទូទាត់តាមអ៊ីនធឺណេត និងតាម QR code។ ប្រព័ន្ធនេះផ្តល់សុវត្ថិភាពខ្ពស់ ដោយមានការផ្ទៀងផ្ទាត់ពីរជាន់ និងការត្រួតពិនិត្យប្រតិបត្តិការបានជាប់លាប់ ដើម្បីការពារការលួចបន្លំ។ វាក៏ជួយអោយអ្នកប្រើប្រាស់សន្សំសំចៃពេលវេលា និងថ្លៃចំណាយ ព្រោះអាចដោះស្រាយប្រតិបត្តិការច្រើនប្រភេទតាមអនឡាញ ដោយមិនចាំបាច់ធ្វើដំណើរ។ ABA ក៏បានផ្តល់ជម្រើសទូទាត់សំរាប់អាជីវកម្មដូចជា ABA KHQR និង ABA Business ដែលជួយអោយទទួលប្រាក់ពីអតិថិជន ឬបង់ប្រាក់ឱ្យដៃគូបានយ៉ាងងាយស្រួល និងរហ័ស។ អ្នកប្រើប្រាស់ទទួលបានអត្ថប្រយោជន៍ចម្បងពីប្រព័ន្ធទូទាត់ឌីជីថលរបស់ ABA គឺភាពងាយស្រួល ភាពរហ័ស ភាពសុវត្ថិភាព ការសន្សំសំចៃពេល និងការចូលដំណើរការបានគ្រប់ពេលវេលា។

**៣.២.២ ការកាត់បន្ថយចំណាយ និងលើកកម្ពស់សេដ្ឋកិច្ចជាតិ**

ធនាគារអេប៊ីអេ (ABA Bank) គឺជាធនាគារដែលមានអភិវឌ្ឍន៍លឿននៅកម្ពុជា ហើយមានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ។ តាមរយៈយុទ្ធសាស្ត្រនៃការកាត់បន្ថយចំណាយ និងការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយបច្ចេកវិទ្យាថ្មីៗ ABA បានអាចអភិវឌ្ឍប្រព័ន្ធសេដ្ឋកិច្ចប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។ ធនាគារនេះបានអនុវត្តន៍នូវការប្រែក្លាយឌីជីថល ដោយផ្តល់សេវាហិរញ្ញវត្ថុតាមប្រព័ន្ធអេឡិត្រូនិកដូចជា ABA Mobile ដែលជួយឱ្យអតិថិជនអាចធ្វើប្រតិបត្តិការបានដោយខ្លួនឯង គ្មានចាំបាច់ទៅកាន់សាខា។

វាបានកាត់បន្ថយថ្លៃដើមដល់ធនាគារ ខណៈពេលដែលបង្កើនភាពងាយស្រួលសម្រាប់អតិថិជន។ បន្ថែមពីនេះ ABA ក៏បានផ្តល់ឱកាសឱ្យអាជីវកម្មខ្នាតតូច និងមធ្យម (SMEs) អាចចូលដំណើរការទុនតាមរយៈឥណទានជាច្រើនប្រភេទ។ វាជួយបង្កើនផលិតភាព និងការបង្កើតការងារ ដែលជាផ្នែកមួយនៃការលើកកម្ពស់សេដ្ឋកិច្ចជាតិ។ ការប្រើប្រាស់បច្ចេកវិទ្យាថ្មីបានកាត់បន្ថយការចំណាយលើធនធានមនុស្ស និងការបោះពុម្ពឯកសារ បង្កើនភាពរហ័សនៃសេវាកម្ម និងការបញ្ចេញបំណុល។

សរុបឡើងវិញ ABA Bank បានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ តាមរយៈការកែលម្អសេវាកម្មហិរញ្ញវត្ថុ កាត់បន្ថយចំណាយក្នុងអង្គភាព និងជំរុញឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗក្នុងវិស័យធនាគារ។

## ៣.៣ យុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យតាមរយៈការទូទាត់សងប្រាក់របស់ធនាគារ

យុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យតាមរយៈការទូទាត់សងប្រាក់របស់ធនាគារអេប៊ីអេមានចំនុចសំខាន់ៗដូចជា:

• ការប្រើប្រាស់បច្ចេកវិជ្ជាសុវត្ថិភាព ដើម្បីធ្វើឱ្យដំណើរការទូទាត់ប្រាក់មានសុវត្ថិភាព។ ឧទាហរណ៍ ព័ត៌មានត្រូវតែលុបបំបាត់ក្នុងការបញ្ជូនប្រាក់ និងការបញ្ជាក់សម្គាល់មុនពេលធ្វើប្រតិបត្តិការនៅក្នុងប្រព័ន្ធបណ្តាញ។

• ការពិនិត្យស្ថានភាពហានិភ័យ គ្រប់គ្រងដោយប្រើប្រព័ន្ធបច្ចេកវិទ្យាដែលអាចវាយតម្លៃ និងកំណត់ថាតើអតិថិជននឹងមានហានិភ័យនៅពេលធ្វើការទូទាត់ប្រាក់ឬអត់។

• ការរៀបចំផែនការប្រឆាំងហានិភ័យ និងវិធានការប្រឆាំងសារប្រហារបណ្តាញ និងការបំពានផ្នែកច្បាប់ ដែលអាចប៉ះពាល់ដល់សុវត្ថិភាពនៃប្រាក់។

• ការត្រួតពិនិត្យ និងបញ្ចូលបរិក្ខារកំណត់ចំណាយ ដើម្បីអោយការទូទាត់សងប្រាក់ត្រូវបានគ្រប់គ្រងនៅក្នុងជម្រើសសុវត្ថិភាព និងទំនាក់ទំនងជាមួយអ្នកទទួល។

• ការស្តារប្រាក់ ប្រសិនបើមានការបាត់បង់ ឬខូចខាតទៀតដោយមានការប្រើប្រាស់ប្រព័ន្ធទូទាត់ប្រាក់ដែលអាចធ្វើការបញ្ជាក់និងបញ្ចប់ការប្រតិបត្តិការជាងមុន។

### ៣.៣.១ យុទ្ធសាស្ត្រហានិភ័យរបស់ធនាគារ និងដំណើរការអនុម័ត

ABA Bank គឺមានការរៀបចំយ៉ាងប្រកបដោយប្រព័ន្ធ និងទំនើប ដើម្បីធានាបាននូវសុវត្ថិភាពហិរញ្ញវត្ថុ និងភាពស្ថិរភាពរបស់ស្ថាប័ន។ ការគ្រប់គ្រងហានិភ័យគឺជាផ្នែកមួយដ៏សំខាន់ក្នុងការអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយតម្លាភាព និងទំនុកចិត្ត។ ធនាគារបានអនុវត្តន៍យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យសំខាន់ៗដូចខាងក្រោម៖

• គ្រប់គ្រងហានិភ័យឥណទាន៖ ABA ប្រើប្រាស់ប្រព័ន្ធវាយតម្លៃឥណទានយ៉ាងម៉ត់ចត់ ដើម្បីធានាថាអតិថិជនដែលទទួលបានឥណទាន មានសមត្ថភាពបង់វិញ។ វាត្រូវការពិនិត្យលើប្រវត្តិឥណទាន ទ្រព្យបញ្ជាក់ និងសមត្ថភាពសងប្រាក់។

• គ្រប់គ្រងហានិភ័យផ្សារហិរញ្ញវត្ថុ៖ ABA មានការតាមដានអត្រាប្តូរប្រាក់ និងអត្រាការប្រាក់យ៉ាងប្រុងប្រយត្ន័ ដើម្បីជៀសវាងការប៉ះពាល់ពីការប្រែប្រួលទីផ្សារ។

• គ្រប់គ្រងហានិភ័យប្រតិបត្តិការណ៍៖ ABA ប្រើប្រាស់បច្ចេកវិទ្យាថ្មី និងគោរពតាមគោលការណ៍សុវត្ថិភាព

ព័ត៌មាន ដូចជា៖ សម្គាល់អត្តសញ្ញាណ អ្នកប្រើប្រាស់ ប្រកការពារ (firewall) និងការស្កេនប្រព័ន្ធបណ្តាញ ដើម្បីការពារការលួចព័ត៌មាន។

• គ្រប់គ្រងហានិភ័យផ្នែកច្បាប់ និងគោលការណ៍រដ្ឋបាល៖ ABA ប្រកាន់ខ្ជាប់តាមច្បាប់ និងបទបញ្ជាផ្សេងៗរបស់ធនាគារជាតិនៃកម្ពុជា និងអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីធានាថាមានភាពស្របច្បាប់ និងតម្លាភាព។

• ផ្តល់ការអប់រំ និងបណ្តុះបណ្តាលបុគ្គលិក៖ ABA ផ្តល់អប់រំយ៉ាងទៀងទាត់ដល់បុគ្គលិក ស្តីពីការរកឃើញហានិភ័យ និងវិធីបណ្តេញ ឬបង្ការហានិភ័យ នៃប្រតិបត្តិការនានា។

• ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហានិភ័យស្វ័យប្រវត្តិ៖ ABA ប្រើប្រាស់ software និងប្រព័ន្ធវាយតម្លៃហានិភ័យដែលបង្ហាញឱ្យឃើញភាពគួរឱ្យជៀសវាង ឬហានិភ័យដែលកើតឡើងក្នុងប្រតិបត្តិការធនាគារ។

### ក. យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់ធនាគារ សាខាម៉ៅសេទុង

យុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យរបស់ធនាគារអេប៊ីអេ (ABA Bank) នៅសាខាម៉ៅសេទុង គឺមានការអនុវត្តយ៉ាងរឹងមាំដើម្បីធានាបាននូវសុវត្ថិភាពក្នុងការបម្រើសេវាធនាគារ ដោយផ្អែកលើគោលការណ៍គ្រប់គ្រងសាមញ្ញ បច្ចេកវិទ្យាទំនើប និងការវាយតម្លៃហានិភ័យជាក់លាក់។ ធនាគារ អេប៊ីអេនៅសាខាម៉ៅសេទុង បានយកបច្ចេកវិទ្យាថ្មីៗមកប្រើប្រាស់ដូចជា ការប្រើប្រាស់កម្មវិធី ABA Mobile ដោយមានការពិនិត្យសុវត្ថិភាពពេញលេញ ព្រមទាំង OTP និង biometric login។ វាជួយកាត់បន្ថយហានិភ័យការបន្លំអត្តសញ្ញាណ និងការចូលប្រើប្រាក់ដោយភាគីទីបី។ នៅសាខានេះ ក៏មានការត្រួតពិនិត្យ និងវាយតម្លៃអតិថិជនជាមុនសិន ដោយក្របខណ្ឌ Know Your Customer (KYC) និងការប្រមូលព័ត៌មានជាក់លាក់ ដើម្បីចៀសវាងហានិភ័យផ្នែកហិរញ្ញវត្ថុ ដូចជាការបោកប្រាស់ ឬការជួញដូរប្រព័ន្ធប្រាក់ខុសច្បាប់។ ព្រមទាំងការតាមដានប្រតិបត្តិការចម្លង។ លើសពីនេះ ABA សាខាម៉ៅសេទុង ក៏មានការបណ្តុះបណ្តាលបុគ្គលិកអោយមានចំណេះដឹងអំពីការគ្រប់គ្រងហានិភ័យ និងការឆ្លើយតបទៅនឹងស្ថានភាពអាសន្ន ដើម្បីធ្វើឱ្យសេវាធនាគាររបស់ខ្លួនមានភាពរឹងមាំ និងទុកចិត្តបានក្នុងតំបន់។

### ខ. ដំណើរការអនុម័ត

ដំណើរការអនុម័ត ជាដំណាក់កាលសំខាន់ក្នុងប្រព័ន្ធគ្រប់គ្រងហានិភ័យ និងការអនុវត្តសេវាកម្មហិរញ្ញវត្ថុរបស់ធនាគារ។ សម្រាប់ធនាគារ អេប៊ីអេ(ABA Bank) នៅសាខាម៉ៅសេទុង ដំណើរការអនុម័តត្រូវបានបែងចែកជាចំណុចសំខាន់ៗដូចខាងក្រោម៖

**១. ការទទួលពាក្យស្នើសុំ:** អតិថិជនស្នើសុំសេវាផ្សេងៗ ដូចជា ឥណទាន បើកគណនី ឬទូទាត់សងប្រាក់។ ព័ត៌មានផ្ទាល់ខ្លួន និងឯកសារភ្ជាប់ត្រូវបានប្រមូលជាមុនសិនតាមបែបបទ Know Your Customer (KYC) ដើម្បីបញ្ជាក់អត្តសញ្ញាណ និងភាពសមស្រប។

**២. ការវាយតម្លៃហានិភ័យ:** បុគ្គលិកធនាគារធ្វើការវិភាគស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន ដូចជា ចំណូលចំណាយ ប្រវត្តិឥណទាន និងការប្រើប្រាស់សេវាកម្មមុននេះ។ ប្រសិនបើជាករណីឥណទាន អ្នកអនុវត្តនឹងត្រួតពិនិត្យថាតើអតិថិជនមានសមត្ថភាពសងបានឬទេ។

**៣. ការពិនិត្យដោយផ្នែកជាប់ពាក់ពន្ធ័:** បន្ទាប់ពីការវាយតម្លៃ បែបបទនិងព័ត៌មាននឹងត្រូវបញ្ជូនទៅផ្នែកជាប់ពាក់ព័ន្ធ ដូចជា Credit Risk, Compliance ឬ Legal (ដោយស្របតាមប្រភេទសេវាកម្ម) ដើម្បីពិនិត្យការអនុវត្តច្បាប់ និងគោលការណ៍គ្រប់គ្រងហានិភ័យ។

**៤. ការអនុម័តចុងក្រោយ:** ប្រធានសាខា ឬអ្នកមានសិទ្ធិអនុញ្ញាត ត្រូវពិនិត្យឡើងវិញនូវឯកសារ ព្រមទាំងលទ្ធផលវាយតម្លៃហានិភ័យ។ បើពេញចិត្តនឹងលក្ខខណ្ឌទាំងអស់ អ្នកនឹងអនុម័ត ឬបដិសេធ ពាក្យស្នើសុំ។

**៥. ការជូនដំណឹងទៅអតិថិជន:** នៅចុងក្រោយ ABA សាខាម៉ៅសេទុងនឹងជូនដំណឹងជាផ្លូវការចំពោះអតិថិជនអំពីលទ្ធផលនៃការអនុម័ត និងដាក់ចេញលក្ខខណ្ឌពាក់ព័ន្ធ (ក្នុងករណីអនុញ្ញាត) ដូចជា ការបង់ត្រឡប់ អត្រាការប្រាក់ កាលបរិច្ឆេទនៃការទូទាត់ និងច្បាប់កិច្ចសន្យា។

# ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី ការរីកចម្រើននៃប្រព័ន្ធទូទាត់តាមឌីជីថលនៅកម្ពុជា រួចមកក្រុមយើងខ្ញុំបានសង្កេតឃើញថាធានាគារ និងហិរញ្ញវត្ថុមានភាពរឹងមាំ រក្សាបានភាពធន់ខ្ពស់។

ចំណុចខ្លាំងនៃប្រព័ន្ធទូទាត់ឌីជីថលនៅកម្ពុជាមានច្រើនណាស់ដែលបានជួយជម្រុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និងផ្តល់ភាពងាយស្រួលក្នុងជីវិតប្រចាំថ្ងៃ។ អត្ថប្រយោជន៍សំខាន់ៗមានដូចខាងក្រោម៖

### ៤.១ ការវិភាគលើចំណុចខ្លាំង

1. **ជាធនាគារធំ និងមានស្ថេរភាពខ្លាំង៖** ធនាគារធំបំផុតក្នុងប្រទេសកម្ពុជា ABA មានទ្រព្យសម្បត្តិ និងប្រាក់កម្ចីច្រើនជាងគេ។
2. **សាខាច្រើន និងសេវាគ្រប់ដណ្តប់ទូទាំងប្រទេស៖** មានសាខាច្រើន + ម៉ាស៊ីន ATM ច្រើន មានសាខា ~100 និង ATM / សេវាឌីជីថលជាច្រើន គ្របដណ្តប់ស្រុកភាគច្រើន។
3. **បច្ចេកវិទ្យាឌីជីថលរីកចម្រើន និងអភិវឌ្ឍលឿន៖** App ABA ល្អជាងគេ ABA Mobile app ងាយប្រើ, មានមុខងារច្រើន, ប្រតិបត្តិការលឿន និងសុវត្ថិភាពល្អ។
4. **ទទួលការវិនិយោគពីធនាគារអន្តរជាតិ៖** (Canada) ជួយអោយ ABA មានប្រាក់ច្រើន និងអភិវឌ្ឍលើបច្ចេកវិទ្យាបន្ថែមជាប្រចាំ។
5. **បានទទួលរង្វាន់អន្តរជាតិជាប្រចាំ** Euromoney ប្តេជ្ញាថា ABA ជាធនាគារល្អបំផុតប្រចាំឆ្នាំ។

### ៤.២ ការវិភាគលើចំណុចខ្សោយ

1. **សេវាកម្មអតិថិជនមិនទាន់ល្អ**
   - អតិថិជនជាច្រើនប្តឹងថា ABA សេវាកម្មនៅសាខា "យឺត", "មិនសូវជួយ", ឬ "មិនទទួលខុសត្រូវល្អ"។
   - តំណាង Call Center ឬ Live Chat មានការឆ្លើយយឺត ឬដោះស្រាយបញ្ហាមិនរហ័ស។
   - បញ្ហានេះអាចប៉ះពាល់ដល់អារម្មណ៍អ្នកប្រើ និងការជឿជាក់លើធនាគារ។
2. **បញ្ហាបច្ចេកទេស និងការរក្សាស្ថេរភាពប្រព័ន្ធ**
   - មានពេលខ្លះ ABA App ឬសេវាស្វ័យប្រវត្តិដាច់ ឬ error ដោយមិនដឹងហេតុផល។
   - ទោះបីជាឌីជីថលខ្លាំង ប៉ុន្តែសេវាកម្មដៃមនុស្ស (human service) គឺខ្សោយ។
   - ប្រព័ន្ធសុវត្ថិភាពអាចមិនបានពិចារណា "user-friendly" ឬអាចមាន bug ខ្លះៗ។
3. **ការប្រកួតប្រជែងខ្លាំងនៅទីផ្សារ** ABA ត្រូវប្រកួតជាមួយធនាគារផ្សេងៗដូចជា:
   - ACLEDA Bank: មានសេវាកម្មអតិថិជនល្អ និងជឿទុកចិត្តខ្ពស់។
   - Canadia Bank: មានសេវាជាច្រើន និងល្បឿនឆ្លើយតបល្អ។
   - Maybank / BIDC / Phillip Bank: កំពុងជំរុញ App និងសេវាឌីជីថលរហ័ស។
   - ប្រសិនបើ ABA មិនបន្តបង្កើនគុណភាពសេវាអតិថិជន, អតិថិជនអាចប្តូរទៅធនាគារផ្សេង។

**4.** ពឹងផ្អែកលើបច្ចេកវិទ្យាច្រើនពេក

- អ្នកប្រើជាច្រើនគឺ "Digital only" (App) ប៉ុន្តែអតិថិជនខ្លះមិនស្គាល់បច្ចេកវិទ្យា។
- អាចបង្កបញ្ហាសម្រាប់អ្នកចាស់ អ្នកនៅជនបទ ឬអ្នកដែលមិនស្គាល់ទូរស័ព្ទ Smartphone។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការស្រាវជ្រាវក្នុងប្រធានបទស្តីពី "**ការរីកចម្រើននៃប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង**" រួចមកក្រុមយើងខ្ញុំ សង្កេតឃើញថាការរីកចម្រើននៃប្រព័ន្ធទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង បានបង្ហាញឱ្យឃើញពីការប្តេជ្ញាចិត្តក្នុងការបំរើសេវាកម្មហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព និងសម័យថ្មី។ ប្រព័ន្ធឌីជីថលបានអភិវឌ្ឍទៅក្នុងទ្រង់ទ្រាយស្វ័យប្រវត្តិកម្ម និងងាយស្រួលប្រើដូចជា Mobile Banking, Internet Banking និងការទូទាត់តាម QR Code ដែលជួយកាត់បន្ថយពេលវេលា និងថ្លៃដើមសម្រាប់អតិថិជន។ តាមរយៈការច្នៃប្រឌិត និងការបញ្ចូលបច្ចេកវិទ្យាថ្មីៗ សាខាម៉ៅសេទុងបានអាចទាក់ទាញអតិថិជនថ្មីៗ ហើយក៏បង្កើនការពឹងផ្អែកលើសេវាឌីជីថលយ៉ាងគួរសម។ អ្វីដែលសំខាន់គឺ ការរីកចម្រើននេះមានភាពសម្របសម្រួលនឹងគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការជំរុញសេដ្ឋកិច្ចឌីជីថល និងការអភិវឌ្ឍប្រទេសជាតិសម្រាប់អនាគត។ ដោយសារតែការរីកចម្រើននេះ ក៏បានកើតមានការប្រឈមមុខជាមួយបញ្ហាផ្សេងៗផងដែរ ដូចជាការព្រួយបារម្ភអំពីសុវត្ថិភាពទិន្នន័យ និងការយល់ដឹងរបស់ប្រជាជនអំពីការប្រើប្រាស់បច្ចេកវិទ្យា។ ទោះជាយ៉ាងណា បើមានការបន្តអភិវឌ្ឍ និងវិនិយោគយ៉ាងត្រឹមត្រូវ ប្រព័ន្ធទូទាត់ឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង នឹងអាចក្លាយជាមូលដ្ឋានសំខាន់សម្រាប់ការផ្លាស់ប្តូរទៅសេដ្ឋកិច្ចឌីជីថលពេញលេញក្នុងពេលអនាគត។

## ៥.២ ការផ្តល់អនុសាសន៍

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវពីអត្ថប្រយោជន៍នៃការទូទាត់តាមឌីជីថលរបស់ធនាគារអេប៊ីអេ សាខាម៉ៅសេទុង ត្រូវបានគាំទ្រពីសំណាក់អ្នកប្រើប្រាស់ជាច្រើននៅក្នុងប្រទេស។ ទន្ទឹមនឹងនេះ ដើម្បីឱ្យការទូទាត់របស់ធនាគារអេប៊ីអេមានការរីកចម្រើន និងមានអ្នកប្រើប្រាស់កាន់តែច្រើនជាងនេះទៅទៀត ក្រុមយើងខ្ញុំសូមផ្តល់អនុសាសន៍ក្នុងន័យស្ថាបនាដូចខាងក្រោម៖

1. **បន្តវិនិយោគលើបច្ចេកវិទ្យាថ្មីៗ**
   - ABA គួរតែបន្តវិនិយោគលើបច្ចេកវិទ្យាប្រកបដោយសុវត្ថិភាព និងមានសមត្ថភាពខ្ពស់ ដើម្បីធានាបាននូវបទពិសោធន៍ល្អសម្រាប់អតិថិជន និងការការពារទិន្នន័យផ្ទាល់ខ្លួនរបស់ពួកគេ។
2. **ពង្រឹងសុវត្ថិភាពបច្ចេកវិទ្យា**
   - ដាក់ចំណាប់អារម្មណ៍លើការពង្រឹងសន្តិសុខសាយប៊ី (cybersecurity) ដើម្បីទប់ស្កាត់ហានិភ័យនៃការបំពានទិន្នន័យ និងបញ្ហាការលួចព័ត៌មានផ្ទាល់ខ្លួន។
3. **ជម្រុញការអប់រំសាធារណៈ**
   - ABA គួរធ្វើសកម្មភាពផ្សព្វផ្សាយ និងបណ្តុះបណ្តាលអតិថិជនអំពីអត្ថប្រយោជន៍ និងវិធីប្រើប្រាស់ប្រព័ន្ធឌីជីថល ដើម្បីបង្កើនការយល់ដឹង និងការទុកចិត្តលើសេវាកម្ម។
4. **ពង្រឹងការផ្តល់សេវាកម្មប្រកបដោយគុណភាព**

- បង្កើនចំនួននិងសមត្ថភាពនៃបុគ្គលិកផ្នែកជំនាញឌីជីថល ដើម្បីអាចឆ្លើយតបនឹងបញ្ហានិងសំណើរបស់អតិថិជនបានយ៉ាងមានប្រសិទ្ធភាព និងទាន់ពេលវេលា។

**5. បង្កើនសេវាកម្មឌីជីថលក្នុងតំបន់ជនបទ**

- ABA គួរតែពង្រីកការចូលដំណើរការទៅកាន់តំបន់ជនបទ ដោយផ្តល់នូវសេវាកម្មឌីជីថលដែលអាចប្រើបានតាមស្មាតហ្វូន ឬឧបករណ៍ឌីជីថលដ៏ងាយស្រួល ដើម្បីជួយអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ខាងក្រៅទីក្រុង។

**6. សហការជាមួយភាគីពាក់ព័ន្ធផ្សេងៗ**

- ABA គួរចូលរួមសហការជាមួយបណ្តាប្រព័ន្ធផ្សេងៗដូចជា អាជ្ញាធរជាតិសម្រាប់អភិវឌ្ឍឌីជីថល ក្រសួងពាក់ព័ន្ធ ឬក៏ស្ថាប័នអន្តរជាតិ ដើម្បីរួមចំណែកលើការបង្កើតបរិយាកាសឌីជីថលដ៏សុវត្ថិភាព និងមានសិទ្ធិគ្រប់គ្រងច្បាស់លាស់

# ឯកសារយោង


១.KHsearch. PHYSICS. (2018, June 27). *ដូចម្ដេចដែលហៅថាប្រព័ន្ធ ?* Retrieved June, 12 2025 from https://www.khsearch.com/qna/4940

២. ACADEMIA.ORY KALIP. *និយមន័យធនាគារ.* Retrieved from https://www.nbc.gov.kh/payment

៣. Facebook Page. IFA. *ប្រវត្តិរបស់ឌីជីថល.* Retrieved June, 12 2025 from https://www.facebook.com/ifa.edu.kh/posts

៤.Videos Lorning. (2022, September 04). *តើពាក្យសារៈប្រយោជន៍មានន័យដូចម្ដេច?* Retrieved June, 12 2025 from https://videoslearning.com/1-937/

៥. ThmeyThmey. PHYSICS. (2018, June 27). *ដូចម្ដេចដែលហៅថាប្រព័ន្ធ ?* Retrieved June, 12 2025 from https://thmeythmey.com/detail/64754

៦.TmeyTmey. (2017, December 27). *យុទ្ធសាស្ត្រ និងវិធីសាស្ត្រមានន័យខុសគ្នាដូចម្ដេច ?* Retrieved from https://thmeythmey.com/detail/59938

៧.Tmey tmey.(2017, December 27). *យុទ្ធសាស្ត្រ និងវិធីសាស្ត្រមានន័យខុសគ្នាដូចម្ដេច ?* Retrieved from https://thmeythmey.com/detail/59938

៨. KHsearch. គ្រប់គ្រង. (2025, May 29). *អ្វីទៅជាយុទ្ធសាស្ត្រ ?* Retrieved June, 12 2025 from https://www.khsearch.com/qna/31418

៩. KHsearch. គ្រប់គ្រង. (2025, May 29). *អ្វីទៅជាការគ្រប់គ្រង ?* Retrieved June, 12 2025 from https://www.khsearch.com/qna/31421

១០. KHsearch. គ្រប់គ្រង. (2019, December 05). *អ្វីជាការគ្រប់គ្រង?* Retrieved June, 12 2025 from https://www.khsearch.com/qna/314110

១១. Facebook Page. 1k Share. ( 2020, November 11). *ពាក្យហានីភ័យ* Retrieved June, 12 2025 from https://web.facebook.com/share/p/16c47kF1nn/

១៣. វិទ្យាស្ថាន វ៉ាន់ដា. (2023). *ការទូទាត់ឌីជីថល.* បោះពុម្ពលើកទី២. ទំព័រទី២៥-២៨ ៣៥ទំព័រ. ភ្នំពេញ។

១៤. វិទ្យាស្ថាន វ៉ាន់ដា. (2022). *ការគ្រងហានិភ័យ.* បោះពុម្ពលើកទី៣ ទំព័រទី៣១-៣២ ៣៩ទំព័រ. ភ្នំពេញ។

១៥.YouTube. ABA Bank. (2022). *សារៈប្រយោជន៍.* Retrieved June, 15 2025 from https://www.youtube.com/watch?v=5sIRIDV8tRo

១៦. AMS. (2023, January 15). *យុទ្ធសាស្ត្រការគ្រងហានិភ័យ.* Retrieved June, 15 2025 from https://economy.ams.com.kh/finance/news/the-use-of-digital-payment-

១៩. Khmer Load. (2024, February 12). *ត្រូវបានគេទទួលស្គាល់សម្រាប់ចូលរួមចំណែក ក្នុងកម្មវិធីចំណេះដឹងហិរញ្ញវត្ថុ របស់ធនាគារជាតិនៃកម្ពុជា* Retrieved from https://www.khmerload.com/article/202274

# ឧបសម្ព័ន

## ឧបសម្ព័នទី១



## ឧបសម្ព័នទី២

